**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

លេខៈ ៤៣ អនក្រ.បក

# អនុក្រឹត្យ
# ស្តីពី
# វិធានការហាមការដាក់ឬការបង្ហាញផលិតផលថ្នាំជក់
# នៅកន្លែងធ្វើការឬកន្លែងសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៦ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសុខាភិបាល
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥១៥/០០៤ ចុះថ្ងៃទី១៨ ខែឧសភា ឆ្នាំ២០១៥ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការត្រួតពិនិត្យផលិតផលថ្នាំជក់
- បានឃើញអនុក្រឹត្យលេខ៦៧ អនក្រ.បក ចុះថ្ងៃទី២២ ខែតុលា ឆ្នាំ១៩៩៧ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងសុខាភិបាល
- បានទទួលការឯកភាពពីគណៈរដ្ឋមន្ត្រីក្នុងសម័យប្រជុំពេញអង្គ នាថ្ងៃទី៤ ខែមីនា ឆ្នាំ២០១៦

## សម្រេច
## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**មាត្រា១ .-**

អនុក្រឹត្យនេះមានគោលបំណងការពារសុខុមាលភាពរបស់ប្រជាជន ការពារនិងទប់ស្កាត់ការរងផ្សែងផលិតផលថ្នាំជក់ដែលបង្កឱ្យមានហានិភ័យសុខភាពដល់អ្នកនៅជុំវិញនិងបរិស្ថាន និងកាត់បន្ថយការប្រើប្រាស់ផលិតផលថ្នាំជក់។

**មាត្រា២ .-**

អនុក្រឹត្យនេះមានគោលដៅកំណត់អំពីវិធានការក្នុងការហាមជក់ ការបង្ហុយផ្សែងផលិតផលថ្នាំជក់ និងទីកន្លែងហាមជក់។

**មាត្រា៣ .-**

អនុក្រឹត្យនេះមានវិសាលភាពអនុវត្តចំពោះការជក់និងការបង្ហុយផ្សែងផលិតផលថ្នាំជក់ នៅក្នុងព្រះរាជាណាចក្រកម្ពុជា។

**មាត្រា៤ .-**

វាក្យសព្ទដែលប្រើក្នុងអនុក្រឹត្យនេះមាននិយមន័យដូចតទៅ៖

- **ផលិតផលថ្នាំជក់** សំដៅដល់ផលិតផលគ្រប់ប្រភេទ ផ្សំឡើងពីសន្លឹកថ្នាំជក់ សរសៃថ្នាំជក់ ឬសារធាតុនៃថ្នាំជក់ ដែលផលិតដោយឧស្សាហករថ្នាំជក់ឬដោយមធ្យោបាយផ្សេងៗទៀត ដែលប្រើប្រាស់សម្រាប់ជក់ដោយផ្ទាល់ឬដោយទម្រង់ផ្សេងៗទៀត រួមមាន ជញ្ជក់ ទំពា ចុក ឬហិត។
- **ការជក់** សំដៅដល់ការប្រើប្រាស់ផលិតផលថ្នាំជក់ដែលកំពុងឆេះឬកំពុងបញ្ចេញចំហាយ ទោះបីជាផ្សែងឬចំហាយនោះត្រូវបានបឺតស្រូបចូលឬបញ្ចេញមកក្រៅក្តី។
- **កន្លែងធ្វើការ** សំដៅដល់កន្លែងដែលជនណាម្នាក់បម្រើការងារជាអចិន្ត្រៃយ៍ឬបណ្តោះអាសន្នក្នុងអគារ ទោះជាការងារនោះទទួលបានប្រាក់កម្រៃឬមិនយកកម្រៃ ដោយស្ម័គ្រចិត្ត ឬកាតព្វកិច្ចក្តី ក្នុងនោះរួមបញ្ចូលទាំងការិយាល័យផ្ទាល់ខ្លួន កន្លែងរួម និងកន្លែងផ្សេងទៀត ដែលជាទូទៅកន្លែងនោះត្រូវបានប្រើប្រាស់ឬចេញចូលក្នុងអំឡុងពេលបំពេញការងារ។ ក្នុងអគារ នៅទីនេះ សំដៅដល់ក្នុងទីចំហក្នុងបន្ទប់ដែលមានដំបូលឬព័ទ្ធដោយជញ្ជាំងមួយឬច្រើនដោយមិនគិតពីប្រភេទសម្ភារៈដែលប្រើប្រាស់សម្រាប់ធ្វើជាដំបូលឬជញ្ជាំង និងដោយមិនគិតថាហេដ្ឋារចនាសម្ព័ន្ធនេះប្រើជាប្រចាំឬបណ្តោះអាសន្នឡើយ។
- **កន្លែងសាធារណៈ:** សំដៅដល់កន្លែង អគារសាធារណៈបិទបាំង មធ្យោបាយដឹកជញ្ជូនសាធារណៈ ដែលសាធារណជនអាចចេញចូលឬប្រើប្រាស់។
- **មធ្យោបាយដឹកជញ្ជូនសាធារណៈ:** សំដៅដល់យានយន្តគ្រប់ប្រភេទ ជាអាទិ៍ រថយន្ត រថភ្លើង ជលយាន អាកាសយាន ដែលដឹកសាធារណជនទូទៅក្នុងគោលបំណងពាណិជ្ជកម្ម។

- **កន្លែងអគារសាធារណៈបិទបាំង** សំដៅដល់កន្លែងសាធារណៈដែលមានដំបូល ជញ្ជាំង ឬរបាំងមួយឬច្រើន មានឬគ្មានទ្វារ ដោយមិនគិតពីប្រភេទសម្ភារៈដែលប្រើប្រាស់សម្រាប់ធ្វើជាដំបូល ជញ្ជាំង ឬរបាំង និងដោយមិនគិតថាកន្លែងនោះត្រូវបានសង់ឬដំឡើងសម្រាប់ជាអចិន្ត្រៃយ៍ឬបណ្តោះអាសន្នឡើយ។
- **គ្រឹះស្ថានសិក្សា** សំដៅដល់មជ្ឈមណ្ឌលអប់រំ សិក្សា បណ្តុះបណ្តាល ដោយគិតចាប់ពីកម្រិតមត្តេយ្យសិក្សាដល់ឧត្តមសិក្សា ទោះជាប្រភេទសាលារៀន ឬវិទ្យាស្ថាន ឬសាកលវិទ្យាល័យ ឬមជ្ឈមណ្ឌលអប់រំបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈគ្រប់កម្រិត។
- **គ្រឹះស្ថានសុខាភិបាល** សំដៅដល់បុស្តិ៍សុខភាព មណ្ឌលសុខភាព មន្ទីរពេទ្យ គ្លីនិកសុខភាព ទាំងរដ្ឋ ទាំងឯកជន ឱសថស្ថាន មន្ទីរពិសោធន៍សុខាភិបាលជាដើម។
- **គ្រឹះស្ថានសាសនា** សំដៅដល់ព្រះវិហារ ធម្មសភា សាលាបុណ្យ កុដិ បណ្ណាល័យ សាលាពុទ្ធិកសិក្សា អាស្រម មណ្ឌលវិបស្សនា វិហារ ស៊ូរ៉ាវ ជាដើម ដែលទីកន្លែងទាំងនោះប្រើប្រាស់ក្នុងគោលបំណងគោរពបូជាសាសនាផ្សេងៗក្នុងព្រះរាជាណាចក្រកម្ពុជា។

## ជំពូកទី២
## សមត្ថកិច្ចគ្រប់គ្រង

**មាត្រា៥ .-**

ក្រសួងសុខាភិបាលជាស្ថាប័នមានសមត្ថកិច្ចក្នុងការណែនាំ ផ្សព្វផ្សាយ អនុវត្ត និងត្រួតពិនិត្យលើការអនុវត្តការហាមការជក់និងការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅកន្លែងធ្វើការនិងកន្លែងសាធារណៈ។ ក្នុងករណីចាំបាច់ ត្រូវសហការជាមួយក្រសួងនិងស្ថាប័ន ព្រមទាំងអង្គការជាតិនិងអង្គការអន្តរជាតិពាក់ព័ន្ធ។

**មាត្រា៦ .-**

ក្រសួងសុខាភិបាលជាស្ថាប័នមានសមត្ថកិច្ចក្នុងការអនុវត្តនិងចាត់វិធានការពិន័យអន្តរការណ៍ដូចមានចែងក្នុងអនុក្រឹត្យនេះ។

## ជំពូកទី៣
## វិធានការហាមឃាត់ការជក់ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់ នៅកន្លែងធ្វើការឬកន្លែងសាធារណៈ

**មាត្រា៧ .-**

ការជក់ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅតាមមធ្យោបាយដឹកជញ្ជូនសាធារណៈ ត្រូវហាមឃាត់។

ការជក់ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់ក្នុងអគារឬក្នុងចម្ងាយ៥ម៉ែត្រពីច្រកចេញចូលនៃទីកន្លែងធ្វើការ កន្លែងអគារសាធារណៈបិទបាំង ត្រូវហាមឃាត់។

ការជក់ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់ក្នុងបរិវេណគ្រឹះស្ថានសុខាភិបាល គ្រឹះស្ថានសិក្សា ទារកដ្ឋាន សួនកុមារ សួនច្បារសាធារណៈ គ្រឹះស្ថានសាសនា សារមន្ទីរ រមណីយដ្ឋានវប្បធម៌ប្រវត្តិសាស្ត្រ កន្លែងហាត់ប្រាណ ស្ថានីយប្រេងឥន្ធនៈ និងកន្លែងងាយឆាបឆេះ ត្រូវហាមឃាត់។

**មាត្រា៨ .-**

គោលការណ៍ណែនាំនិងការចាត់វិធានការចាំបាច់ផ្សេងៗទាក់ទងទៅនឹងទីកន្លែងហាមឃាត់ និងកន្លែងហាមឃាត់ផ្សេងៗទៀត ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា៩ .-**

អ្នកគ្រប់គ្រង ឬម្ចាស់កន្លែងធ្វើការ ឬម្ចាស់កន្លែងសាធារណៈ ត្រូវបិទផ្សាយឬដាក់បម្រាមអំពីការហាមការជក់ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់នៅតាមផ្លូវចូលនិងកន្លែងសមស្របផ្សេងទៀតដែលឱ្យសាធារណជនអាចមើលឃើញច្បាស់។ បម្រាមនេះត្រូវដាក់បញ្ជាក់អំពីប្រាក់ពិន័យនិងលេខទូរសព្ទសមត្ថកិច្ចសម្រាប់ទាក់ទង ដែលត្រូវដាក់នៅតាមកន្លែងជាក់ស្តែង។

ស្លាកបម្រាមនៃការហាមការជក់ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាល។

**មាត្រា១០ .-**

អ្នកគ្រប់គ្រង ឬម្ចាស់កន្លែងធ្វើការ ឬម្ចាស់កន្លែងសាធារណៈត្រូវបង្គាប់មិនឱ្យជក់ឬបង្ហុយផ្សែងផលិតផលថ្នាំជក់ចំពោះជនណាដែលមិនអនុវត្តតាមស្លាកបម្រាមហាមជក់និងត្រូវសហការជាមួយសមត្ថកិច្ច ដើម្បីចាត់វិធានការឱ្យទាន់ពេលវេលា។

**មាត្រា១១ .-**

នៅកន្លែងធ្វើការ កន្លែងសាធារណៈ និងកន្លែងផ្សេងៗទៀត ដែលត្រូវបានហាមឃាត់មិនឱ្យជក់ និងបង្ហុយផ្សែងផលិតផលថ្នាំជក់ មិនត្រូវដាក់តាំងឬបង្ហាញប្រដាប់គោះបារីឬរូបភាពប្រដាប់គោះបារី ទោះនៅក្នុងទម្រង់ ទំហំ និងប្រភេទណាក៏ដោយ។

**មាត្រា១២ .-**

ជនណាដែលមិនអនុវត្តតាមបម្រាមស្តីពីការហាមជក់ឬបង្ហុយផ្សែងផលិតផលថ្នាំជក់ ជនណាមួយផ្សេងទៀត ត្រូវរាយការណ៍ជូនសមត្ថកិច្ច ដើម្បីចាត់វិធានការឱ្យទាន់ពេលវេលា។

## ជំពូកទី៤
## បទប្បញ្ញត្តិដោយឡែក

**មាត្រា១៣ .-**

នៅអាកាសយានដ្ឋាន អាចមានបន្ទប់សម្រាប់ជក់ឬបង្ហុយផ្សែងផលិតផលថ្នាំជក់។

## ជំពូកទី៥
## ពិន័យអន្តរការណ៍

**មាត្រា១៤ .-**

ជនណាមិនគោរពតាមបទប្បញ្ញត្តិមាត្រា៧នៃអនុក្រឹត្យនេះត្រូវពិន័យអន្តរការណ៍ជាប្រាក់២០ ០០០ (ពីរម៉ឺន)រៀល។

**មាត្រា១៥ .-**

អ្នកគ្រប់គ្រង ឬម្ចាស់កន្លែងធ្វើការ ឬម្ចាស់កន្លែងសាធារណៈដែលមិនអនុវត្តតាមបទប្បញ្ញត្តិ មាត្រា៩ មាត្រា១០ និងមាត្រា១១នៃអនុក្រឹត្យនេះត្រូវពិន័យអន្តរការណ៍ជាប្រាក់៥០ ០០០(ប្រាំម៉ឺន)រៀល។ ក្នុងករណីមិនរាងចាលត្រូវពិន័យទ្វេដង។

**មាត្រា១៦ .-**

បែបបទនៃការបង់ប្រាក់ពិន័យ ការគ្រប់គ្រងបង្កាន់ដៃប្រាក់ពិន័យ និងការគ្រប់គ្រងប្រាក់ចំណូលបានមកពីការពិន័យ ត្រូវកំណត់ដោយប្រកាសរួមរបស់រដ្ឋមន្ត្រីក្រសួងសុខាភិបាលនិងរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៦
## អន្តរប្បញ្ញត្តិ

**មាត្រា១៧ .-**

បន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន អ្នកគ្រប់គ្រង ឬម្ចាស់កន្លែងធ្វើការ ឬម្ចាស់កន្លែងសាធារណៈ មានរយៈពេល៦(ប្រាំមួយ)ខែ ដើម្បីរៀបចំដាក់ស្លាកបម្រាមស្តីពីការហាមជក់ឬការបង្ហុយផ្សែងផលិតផលថ្នាំជក់។

## ជំពូកទី៧
## អវសានប្បញ្ញត្តិ

**មាត្រា១៨ .-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះត្រូវទុកជានិរាករណ៍។

**មាត្រា១៩ .-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសុខាភិបាល រដ្ឋមន្ត្រីគ្រប់ក្រសួងនិងប្រធានគ្រប់ស្ថាប័នដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះតាមភារកិច្ចរៀងៗខ្លួនចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ មីនា ឆ្នាំ២០១៦

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល :**
- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១៩
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ